Australian Government
Services Australia

KHMER

# The Paid Parental Leave scheme

# ព័ត៌មានសម្រាប់និយោជក

Paid Parental Leave scheme អនុញ្ញាតឱ្យនិយោជក ផ្តល់ពេលវេលាឈប់សម្រាកពីការងារដល់និយោជិតរបស់ខ្លួនតាមរយៈ  Parental Leave Pay (ប្រាក់ឧបត្ថម្ភការឈប់សម្រាកសម្រាប់ឪពុកម្តាយនៅពេលទារកកើតមក និងការសុំកូន)។

Parental Leave Pay គឺជាប្រាក់ឧបត្ថម្ភផ្តល់ជូនពួកគេដើម្បីឈប់សម្រាកពីការងារសម្រាប់ថែរក្សាកូនទើបនឹងកើត ឬកូនដែលបានសុំយកមកចិញ្ចឹមក្នុងពេលថ្មីៗនេះ ឬក្នុងករណីដែលនិយោជិតជួបប្រទះនូវការកើតកូនដែលស្លាប់ក្នុងផ្ទៃ ឬការស្លាប់របស់ទារក។

និយោជិត អាចរួមមាន៖

- និយោជិតធ្វើការពេញម៉ោង និងក្រៅម៉ោង
- និយោជិតធ្វើការម្តងម្កាល
- អ្នកម៉ៅការ
- និយោជិតធ្វើការតាមរដូវកាល។

និយោជិតរបស់អ្នកចាំបាច់ត្រូវដាក់ពាក្យស្នើសុំ Parental Leave Pay មកយើង និងពិភាក្សាជាមួយអ្នកអំពីការរៀបចំការឈប់សម្រាក។

ដើម្បីទទួលបាន Parental Leave Pay និយោជិតត្រូវតែបំពេញតាមច្បាប់ស្តីពីការស្នាក់នៅ និងការងារ ហើយនិងការធ្វើតេស្តលើប្រាក់ចំណូល។

ពួកគេក៏ត្រូវបំពេញតាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោមផងដែរ៖

- រស់នៅក្នុងប្រទេសអូស្ត្រាលី
- មានកូនទើបនឹងកើត ឬកូនដែលបានសុំយកមកចិញ្ចឹមក្នុងពេលថ្មីៗនេះ
- បានធ្វើការឱ្យអ្នកយ៉ាងហោចណាស់ 12 ខែ មុនកាលបរិច្ឆេទដែលរំពឹងថានឹងសម្រាលកូន ឬទទួលយកកូនមកចិញ្ចឹម
- បន្តធ្វើជានិយោជិតរបស់អ្នករហូតដល់យ៉ាងហោចណាស់ចប់អំឡុងពេល Paid Parental Leave របស់ពួកគេ
- រំពឹងថានឹងទទួលបាន Parental Leave Pay យ៉ាងហោចណាស់ 8 សប្តាហ៍។

យើងនឹងសម្រេចចិត្តថាតើនិយោជិតរបស់អ្នកអាចទទួលបាន Parental Leave Pay ឬអត់ ដោយផ្អែកលើព័ត៌មានដែលពួកគេបានផ្តល់ឱ្យយើងនៅក្នុងពាក្យសុំរបស់ពួកគេ។

ប្រសិនបើពួកគេអាចទទួលបាន Parental Leave Pay យើងនឹងផ្តល់ប្រាក់នោះទៅឱ្យអ្នក ដើម្បីឱ្យអ្នកបន្តផ្តល់ជូននិយោជិតរបស់អ្នកតាមរយៈប្រព័ន្ធទូទាត់បៀវត្សរ៍ធម្មតារបស់អ្នក។ យើងនឹងជូនដំណឹងដល់អ្នកអំពីពេលវេលាដែលអ្នកត្រូវធ្វើការទូទាត់ប្រាក់ទាំងនោះ។

អ្នកមិនចាំបាច់ត្រូវផ្តល់ Parental Leave Pay ដល់និយោជិតរបស់អ្នក មុនពេលអ្នកទទួលបានប្រាក់ពីយើងនោះទេ។

ដើម្បីចូលរួមក្នុងគម្រោងនេះ អ្នកត្រូវចុះឈ្មោះអាជីវកម្មរបស់អ្នកជាមួយយើង។

## របៀបចុះឈ្មោះអាជីវកម្មរបស់អ្នក

អ្នកត្រូវចុះឈ្មោះសម្រាប់ Paid Parental Leave scheme នៅតាមអនឡាញ៖

- បង្កើតគណនីដែលមានសុវត្ថិភាព Provider Digital Access Account (PRODA) ទាំងសម្រាប់បុគ្គល និងសម្រាប់អាជីវកម្ម ដោយចូលទៅកាន់គេហទំព័រ **servicesaustralia.gov.au/proda**
  - **កំណត់ចំណាំ៖** អ្នកនឹងត្រូវការ Australian Business Number (ABN) (លេខអាជីវកម្មអូស្ត្រាលី) របស់អ្នកដើម្បីធ្វើការចុះឈ្មោះ។
- ភ្ជាប់អាជីវកម្មរបស់អ្នកទៅនឹងសេវាកម្មអនឡាញមជ្ឈមណ្ឌលអាជីវកម្ម (Business Hub) តាមរយៈ PRODA។
- ចុះឈ្មោះសម្រាប់គម្រោង Paid Parental Leave នៅក្នុងមជ្ឈមណ្ឌលអាជីវកម្ម។

ប្រសិនបើអ្នកមិនអាចចុះឈ្មោះតាមអនឡាញបានទេ អ្នកអាចទូរសព្ទមកយើងតាមលេខ **131 158**។

## របៀបដែលយើងនឹងទូទាត់ប្រាក់ជូនអ្នក

យើងនឹងផ្ទេរប្រាក់ Parental Leave Pay ចូលទៅក្នុងគណនីធនាគារអាជីវកម្មរបស់អ្នក 7 ថ្ងៃ មុនកាលបរិច្ឆេទកំណត់នៃវដ្តទូទាត់បៀវត្សរ៍ធម្មតារបស់និយោជិតអ្នក។

## សិទ្ធិទទួលបានការឈប់សម្រាក

Paid Parental Leave scheme មិនផ្លាស់ប្តូរសិទ្ធិទទួលបានការឈប់សម្រាកដែលមានស្រាប់របស់និយោជិតអ្នក ឬផ្តល់សិទ្ធិឈប់សម្រាកថ្មីដល់ពួកគេនោះទេ។

និយោជិតរបស់អ្នកអាចស្នើសុំយកការឈប់សម្រាកផ្សេងទៀត (ដែលមានបៀវត្សរ៍ ឬគ្មានបៀវត្សរ៍) ក្នុងពេលតែមួយដែលពួកគេទទួលបាន Parental Leave Pay។

## របៀបដែលគម្រោងនេះជួយដល់អាជីវកម្ម និងនិយោជិតរបស់អ្នក

**Paid Parental Leave schemeជួយអ្នកក្នុងការ៖**

- រក្សានិយោជិតដែលមានតម្លៃ និងមានជំនាញដោយមិនចាំបាច់ឱ្យអ្នកបង់ប្រាក់ Parental Leave Pay
- បង្កើតកន្លែងធ្វើការដែលគាំទ្រដល់គ្រួសារ
- រក្សានិយោជិតដែលទើបមានកូនថ្មី ឱ្យបន្តធ្វើការបានយូរជាងមុន។

**គម្រោងនេះជួយនិយោជិតរបស់អ្នក៖**

- ទទួលបានជំនួយផ្នែកហិរញ្ញវត្ថុ ខណៈពេលដែលពួកគេឈប់សម្រាកពីការងារដើម្បីមើលថែកូនថ្មី
- មានតុល្យភាពរវាងការងារ និងជីវិតគ្រួសារ។

## សម្រាប់ព័ត៌មានបន្ថែម

- ចូលទៅកាន់ **servicesaustralia.gov.au/pplemployers** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស
- ចូលទៅកាន់ **servicesaustralia.gov.au/proda** ដើម្បីទទួលបានព័ត៌មានអំពីការចុះឈ្មោះអាជីវកម្មរបស់អ្នក
- ចូលទៅកាន់ **servicesaustralia.gov.au/yourlanguage** ជាកន្លែងដែលអ្នកអាចអាន ស្តាប់ ឬមើលព័ត៌មានជាភាសារបស់អ្នក។
- សូមទូរសព្ទមកយើងតាមលេខ **131 158** ឬ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នក។

Australian Government
Services Australia

ENGLISH

# The Paid Parental Leave scheme

# Information for employers

The Paid Parental Leave scheme allows employers to give their employees time off work through Parental Leave Pay.

Parental Leave Pay is a payment for them to take time off work to care for a newborn or recently adopted child or where the employee has had a stillbirth or infant death.

Employees can include:

- full time and part time workers
- casual workers
- contractors
- seasonal workers.

Your employee needs to apply for Parental Leave Pay with us and talk to you about leave arrangements.

To get Parental Leave Pay, the employee must meet our residence rules and work and income tests.

They also need to meet all the following:

- live in Australia
- have a newborn or recently adopted child
- has worked for you for at least 12 months before the expected date of birth or adoption
- continue to be your employee until at least the end of their Paid Parental Leave period
- expected to get at least 8 weeks of Parental Leave Pay.

We decide if your employee can get the Parental Leave Pay from the information they tell us in their claim.

If they can get Parental Leave Pay, we will give you the funds to give to your employee through your normal payroll. We will tell you when you need to pay them.

You do not have to give Parental Leave Pay to your employee before you get the funds from us.

To be part of this scheme, you need to register your business with us.

## How to register your business

You need to register for the Paid Parental Leave scheme online:

- Set up both an individual and a business secure Provider Digital Access Account (PRODA) by going to **servicesaustralia.gov.au/proda**

  - **Note:** You will need your Australian Business Number (ABN) to register.
- Link your business to the Business Hub online services via PRODA.
- Register for the Paid Parental Leave scheme in Business Hub.

If you cannot register online, you can call us on **131 158**.

## How we will pay you

We will transfer the Parental Leave Pay funds into your business bank account 7 days before your employee's usual pay cycle cut off.

## Leave entitlements

The Paid Parental Leave scheme does not change any of your employee's existing leave entitlements or give them new leave entitlement.

Your employees may ask to take other leave (paid or unpaid) at the same time they get Parental Leave Pay.

## How the scheme helps your business and your employees

**The Paid Parental Leave scheme helps you:**

- keep valuable and skilled staff without you having to fund Parental Leave Pay
- have a family friendly workplace
- keep new parents in the workforce longer.

**The scheme helps your employees to:**

- have financial help while they take time off work to care for a new child
- have balance between work and family life.

## For more information

- Go to **servicesaustralia.gov.au/pplemployers** for more information in English
- Go to **servicesaustralia.gov.au/proda** for information about registering your business
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch information in your language
- Call us on **131 158** or **131 202** to speak to us in your language.





OFFICIAL